អង្គភាពសវនកម្មផ្ទៃក្នុង

# អត្ថបទប្រចាំខែមីនា

លេខ ២៧/២៤ ចេញផ្សាយ ខែមីនា ឆ្នាំ២០២៤

## គោលបំណងនៃការគ្រប់គ្រងហិរញ្ញវត្ថុ



ការគ្រប់គ្រងហិរញ្ញវត្ថុ គឺសំដៅដល់ការរៀបចំផែនការហិរញ្ញវត្ថុ ការរកប្រភព ការបែងចែក ការត្រួតពិនិត្យការប្រើប្រាស់ហិរញ្ញវត្ថុ និងការរាយការណ៍ពីធនធានហិរញ្ញវត្ថុរបស់ស្ថាប័នដើម្បីសម្រេចឱ្យបាននូវប្រសិទ្ធភាព និងប្រសិទ្ធផលជាអតិបរមានៃលទ្ធផលប្រតិបត្តិការ។ សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈគឺជាសកម្មភាព ឬមធ្យោបាយផ្សេងៗរបស់រដ្ឋក្នុងដំណើរការកៀរគរចំណូល និងការទូទាត់ចំណាយក្នុងនោះការចំណាយត្រូវប្រកបដោយវិចារណកម្មត្រឹមត្រូវដើម្បីរួមចំណែកសេដ្ឋកិច្ចឱ្យមានការរីកចម្រើន និងការអភិវឌ្ឍប្រកបដោយចីរភាព។ គោលបំណងនៃការគ្រប់គ្រងហិរញ្ញវត្ថុមានចំនួន ៤ រួមមាន÷

### ១. រក្សាស្ថិរភាពហិរញ្ញវត្ថុ

ការគ្រប់គ្រងហិរញ្ញវត្ថុជួយគ្រប់គ្រងលំហូរសាច់ប្រាក់ឱ្យបានល្អ និងធានាបានថាស្ថាប័នមានសាច់ប្រាក់គ្រប់គ្រាន់ដើម្បីប្រតិបត្តិការរយៈពេលវែង និងគ្របដណ្តប់ចំណាយរយៈពេលខ្លី និងវែង។

### ២. បង្កើនប្រាក់ចំណេញអតិបរមា

ការគ្រប់គ្រងហិរញ្ញវត្ថុ នឹងកំណត់ឱកាសសម្រាប់បង្កើនប្រាក់ចំណេញប្រកបដោយប្រសិទ្ធភាព និងការកាត់បន្ថយហានិភ័យប្រតិបត្តិការ។ គោលដៅនេះសម្រេចបានដោយការវិនិយោគដ៏ឆ្លាតវៃ និងការយល់ច្បាស់ពីស្ថានភាពទីផ្សារ និងសេដ្ឋកិច្ច។

### ៣. ការគ្រប់គ្រងចំណាយ

ការគ្រប់គ្រងហិរញ្ញវត្ថុនឹងផ្តល់លទ្ធភាពក្នុងការប្រើប្រាស់ដើម្បីផ្តល់ ឬបង្កើតហិរញ្ញប្បទានសម្រាប់កំណើនសាច់ប្រាក់នាពេលអនាគត ឬដើម្បីគ្រប់គ្រងចំណាយរយៈពេលខ្លី។ ការគ្រប់គ្រងចំណាយបានត្រឹមត្រូវអាចធ្វើឱ្យប្រសើរឡើងនូវស្ថានភាពហិរញ្ញវត្ថុ និងស្ថិរភាពស្ថាប័នទាំងមូល។

### ៤. ការពារផលប្រយោជន៍ម្ចាស់ភាគហ៊ុន

ការគ្រប់គ្រងហិរញ្ញវត្ថុផ្តល់ប្រយោជន៍ខ្ពស់ដល់ម្ចាស់ភាគហ៊ុន ក្នុងដំណើរការបោះឆ្នោត ឬការសម្រេចចិត្ត រួមបញ្ចូលទាំងការវាយតម្លៃហានិភ័យដែលទាក់ទង នឹងជម្រើសនៃការវិនិយោគផ្សេងដែលសមស្របបំផុតសម្រាប់ស្ថានភាពរបស់ស្ថាប័ន។



អត្ថបទ÷ លោក **ថូ គឹមហាក់**

**ឯកសារយោង÷** ឧត្តមានុវត្តន៍នៃការគ្រប់គ្រងហិរញ្ញវត្ថុរបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃ **អ.ស.ហ**

អត្ថបទអប់រំខ្លីៗស្តីពីសវនកម្មត្រូវបានរៀបរៀងដោយមន្ត្រីរបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃ អ.ស.ហ.

ទស្សនៈដែលមាននៅក្នុងអត្ថបទនេះ មិនមែនជាទស្សនៈរបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃ អ.ស.ហ. ទេ ប៉ុន្តែជាទស្សនៈរបស់អ្នករៀបរៀងផ្ទាល់ខ្លួន ឬរបស់ក្រុមការងារ។

Facebook Telegram Website